**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាឧទ្ធរណ៍**

**<u>សំណុំរឿងព្រហ្មទណ្ឌ</u>**
លេខ ៧០៧
ចុះថ្ងៃទី ១៧-០៦-២០២១
**<u>សាលដីកា</u>**
លេខ ៧២ ក្រ.សវ
ចុះថ្ងៃទី០៧-១២-២០២១

## <u>តាងនាមប្រជារាស្ត្រខ្មែរ</u>
## <u>សាលាឧទ្ធរណ៍ភ្នំពេញ</u>

បង្កើតតាមច្បាប់ស្តីពីការចាត់តាំង និងសម្ពភាពរបស់សាលាជម្រះក្តី ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ: នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ បើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ភ្នំពេញ នាថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលមានសមាសភាពដូចតទៅ៖

**<u>សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ</u>**

ឯកឧត្តម [redacted] ជាប្រធានក្រុមប្រឹក្សា
លោកស្រី [redacted] ជាចៅក្រមប្រឹក្សា
លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

**<u>តំណាងមហាអយ្យការ</u>**

ឯកឧត្តម [redacted] ជាអគ្គព្រះរាជអាជ្ញារង

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃសំណុំរឿងព្រហ្មទណ្ឌលេខ ៧០៧ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដោយមាន:

+<u>ជនជាប់ចោទ</u>:

១-ឈ្មោះ[redacted]ឡុននារីរតន៍ ភេទស្រី អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ បេឡាការផ្នែកទទួលប្រាក់ពន្ធនៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក ទីកន្លែង កំណើតនៅសង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ទីលំនៅមុនពេលឃុំខ្លួ[redacted] លេខ១០ ភូមិក្រាំងដូនតី សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted] រស់ ម្តាយឈ្មោ[redacted] រស់ ប្តីឈ្មោះ[redacted] រស់ មានកូនចំនួន ០២នាក់ ទោសពីមុនគ្មាន ជានីតិជន។

-មានមេធាវីការពារក្តីលោ[redacted]សុគន្ធ និងមេធាវី [redacted]វិបុល។

២-ឈ្មោះ[redacted]បញ្ញាសុជាតា ភេទស្រី អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ បុគ្គលិកធនាគារវឌ្ឍនៈអាស៊ីចំកាត់ ទីកន្លែងកំណើតនៅសង្កាត់ផ្សារកណ្តាលទី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទីលំនៅមុនពេលឃុំខ្លួននៅផ្ទះលេខ៧១៧ ផ្លូវលេខK៤ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ





Scanned with CamScanner

រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted]ចិត្រា "រស់" ម្តាយឈ្មោ[redacted]"រស់" ប្តីឈ្មោ[redacted]រស់" មានកូនចំនួន ០៣នាក់ ទោសពីមុនគ្មាន ជានីតិជន។

-មានមេធាវីការពារក្តីលោក[redacted]ឆ្នុល។

៣-ឈ្មោះ[redacted]មុខវណ្ណាចរិយា ភេទស្រី អាយុ ៣០ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរមន្ត្រីជាន់ខ្ពស់ត្រួតពិនិត្យផ្នែកទទួលប្រាក់ពន្ធនៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក ទីកន្លែងកំណើតនៅភូមិក្បាលហុង ឃុំផ្ទះព្រៃ ស្រុកសំពៅមាស ខេត្តពោធិ៍សាត់ ទីលំនៅមុនពេលឃុំខ្លួននៅ[redacted] ផ្លូវលេខ០៤ សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted] "រស់" ម្តាយឈ្មោះ[redacted]"ស្លាប់" ប្តីឈ្មោះ[redacted] "រស់" មានកូនចំនួន ០២នាក់ ទោសពីមុនគ្មាន ជានីតិជន។

-មានមេធាវីការពារក្តីលោក[redacted]ចិនធឿន។

៤-ឈ្មោះ[redacted]រចនា ភេទស្រី អាយុ ៣៩ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរអនុប្រធានប្រតិបត្តិស្នាក់ការកណ្តាលទទួលបន្ទុកផ្នែកទទួលប្រាក់ពន្ធ និងគម្រោងរដ្ឋាភិបាលនៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក ទីកន្លែងកំណើតនៅសង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទីលំនៅមុនពេលឃុំខ្លួ[redacted]សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោ[redacted]ស្លាប់" ម្តាយឈ្មោះ[redacted]ស្លាប់" ប្តីឈ្មោះ[redacted] "រស់" មានកូនចំនួន ០២នាក់ ទោសពីមុនគ្មាន ជានីតិជន។

-មានមេធាវីការពារក្តីលោក[redacted]ចិនរ៉ា។

៥-ឈ្មោះ[redacted] សុធាយ ភេទប្រុស អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរមន្ត្រីជាន់ខ្ពស់ផ្នែកព័ត៌មានវិទ្យា (IT) និងជាប្រធានក្រុមប្រព័ន្ធស្នូលធនាគារនៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក ទីកន្លែងកំណើតនៅភូមិ១ ឃុំកំពេញ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ទីលំនៅមុនពេល [redacted]ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រស់" ម្តាយឈ្មោះ[redacted]"រស់" ប្រពន្ធឈ្មោះ[redacted]"រស់" មានកូនចំនួន ០២នាក់ ទោសពីមុនគ្មាន ជានីតិជន។

-មានមេធាវីការពារក្តីលោក[redacted]ចិនធឿន។

ជនជាប់ចោទទាំង ៥នាក់ **ជាប់ចោទពីបទ** **រំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬ បុគ្គលផ្សេងទៀត** ប្រព្រឹត្តនៅចំណុចស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក ផ្លូវព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីដើមខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ។

៦-ឈ្មោះ[redacted] ហៀង ភេទប្រុស អាយុ ៤៣ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរបុគ្គលិកផ្នែកសន្តិសុខ និងបើកបររថយន្តនៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក ទីកន្លែងកំណើតនៅភូមិព្រាំងពង្រ ឃុំកុមារាជា ស្រុកបាទី ខេត្តតាកែវ ទីលំនៅមុនពេ[redacted] សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោ[redacted]"រស់" ម្តាយឈ្មោះ[redacted] "រស់" ប្រពន្ធឈ្មោះ [redacted]"រស់" មានកូនចំនួន ០២នាក់ ទោសពីមុនគ្មាន ជានីតិជន។

-មានមេធាវីការពារក្តីលោក[redacted]សម្បត្តិ។



Scanned with CamScanner

៧-ឈ្មោះ [redacted]ស៊ីមន្ថា ភេទប្រុស អាយុ ៣៩ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរមន្ត្រីនាយកដ្ឋានត្រួតពិនិត្យ និងវាយតម្លៃនៅក្រសួងមុខងារសាធារណៈ ទីកន្លែងកំណើតនៅអូរឬស្សី៣ ក្រុងភ្នំពេញ ទីលំនៅមុនពេលឃុំខ្លួននៅផ្ទះ [redacted] ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រស់" ម្ដាយឈ្មោះ [redacted] "រស់" ប្រពន្ធឈ្មោះ [redacted] "រស់" មានកូនចំនួន ០២នាក់ ទោសពីមុនគ្មាន ជានីតិជន។

-មានមេធាវីការពារក្ដីលោក [redacted] សុគន្ធ និងមេធាវី [redacted] **ទិមុល**។

ជនជាប់ចោទទាំង ០២នាក់ **ជាប់ចោទពីបទ** **សមគំនិតក្នុងអំពើរំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬ បុគ្គលផ្សេងទៀត** ប្រព្រឹត្តនៅចំណុចស្នាក់ការកណ្ដាលធនាគារកាណាឌីយ៉ា អ.ក ផ្លូវព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីដើមខែមករា ឆ្នាំ ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោស តាមបញ្ញត្តិមាត្រា ២៩ និងមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្ដឹងរដ្ឋប្បវេណី និងជាជនរងគ្រោះ **ធនាគារកាណាឌីយ៉ា ក.អ** ( CANADIA BANK PLC.) មានអាសយដ្ឋានស្ថិតនៅអគារលេខ ៣១៥ វិថីព្រះអង្គឌួងកែងនឹងមហាវិថីព្រះមុនីវង្ស សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ដែលមានលោក [redacted] ឆារស់ ជាអគ្គនាយករងប្រតិបត្តិធនាគារកាណាឌីយ៉ា អ.ក ជាអ្នកតំណាង។

-មានមេធាវីការពារសិទ្ធិលោក [redacted] ប៊ុរមុនី និងមេធាវី [redacted] **កនិកា**។

**អំពីអង្គហេតុ**

មុនពេលកើតហេតុឈ្មោះ [redacted] វឌ្ឍននារីរតន៍ ជាបុគ្គលិកនៅស្នាក់ការកណ្ដាលធនាគារកាណាឌីយ៉ា ក.អ ទទួលបន្ទុកផ្នែកបង់ប្រាក់ពន្ធជូនរដ្ឋពីអតិថិជន តាមរយៈការវេរចូលគណនីរបស់អគ្គនាយកពន្ធដារ ហើយក្នុងរយៈពេលដែលបានទទួលតួនាទីនេះឈ្មោះ [redacted] វឌ្ឍននារីរតន៍ បានធ្វើសកម្មភាពកែបំបាត់ប្រាក់របស់ធនាគារកាណាឌីយ៉ា ក.អ ជាច្រើនលើក។ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ ឈ្មោះ [redacted] វឌ្ឍននារីរតន៍ បានធ្វើសកម្មភាពទៀត ដោយបានយកប្រាក់ចេញពីធនាគារកាណាឌីយ៉ា ក.អ ចំនួន ៦.៦១០.០០០$ (ប្រាំមួយលានហុកមួយម៉ឺន)ដុល្លារអាមេរិក ច្រកក្នុងថង់ខ្មៅចំនួន ៣ថង់ ហើយបានហៅឈ្មោះ [redacted] បញ្ញាសុជាតា ដែលជាអតីតបុគ្គលិកធនាគារកាណាឌីយ៉ា ក.អ មកជួយនាំសន្តិសុខ ៣ នាក់ជញ្ជូនប្រាក់ទាំងនេះពីជាន់ផ្ទាល់ដី ឡើងទៅជាន់ទី៥ នៃអគារស្នាក់ការកណ្ដាលធនាគារកាណាឌីយ៉ា ក.អ រួចរង់ចាំនៅជាន់ទី៥ ប្រហែលកន្លះម៉ោងទើបឈ្មោះ [redacted] ស៊ីមន្ថា ជាប្ដីរបស់ឈ្មោះ [redacted] វឌ្ឍននារីរតន៍ មកដល់ រួចបញ្ជូនថង់ប្រាក់ទាំងនោះដាក់ក្នុងរថយន្ត ហើយដឹកចេញទៅបាត់។ ក្នុងការប្រព្រឹត្តរបស់ឈ្មោះ [redacted] វឌ្ឍននារីរតន៍ នេះមានការសម្របសម្រួលពីឈ្មោះ [redacted] ហៀង ជាសន្តិសុខ និងជាអ្នកបើកបររថយន្តនៅស្នាក់ការកណ្ដាលធនាគារកាណាឌីយ៉ា ក.អ ផងដែរ ដោយឈ្មោះ [redacted] ហៀង នេះបានជួយលើកថង់ប្រាក់ពីជាន់ផ្ទាល់ដីទៅកាន់ជាន់ទី៥ នៃអគារកណ្ដាលធនាគារកាណាឌីយ៉ា ក.អ។ រីឯឈ្មោះ [redacted] សុវណ្ណចរិយា និងឈ្មោះ [redacted] រចនា ជាបុគ្គលិកមានតួនាទីត្រួតពិនិត្យការងាររបស់ឈ្មោះ [redacted] វឌ្ឍននារីរតន៍ ដោយផ្ទាល់នោះបានឃុបឃិតគ្នាមិនរាយការណ៍ជូនថ្នាក់គ្រប់គ្រងធនាគារឡើយ ដោយឈ្មោះ [redacted] សុវណ្ណចរិយា បានទទួលប្រាក់ពីឈ្មោះ [redacted] វឌ្ឍននារីរតន៍ រួចយកទុកក្នុងថតតុរបស់ខ្លួន រហូតដល់ពេលចប់ម៉ោងធ្វើការក៏យកប្រាក់នេះដាក់ចូលកាបូបរបស់ខ្លួន រួចចេញទៅផ្ទះដោយមានឈ្មោះ [redacted] ស៊ីមន្ថា ជាប្ដីបានមកទទួល។ ក្នុងការប្រព្រឹត្តនេះឈ្មោះ [redacted] បញ្ញាសុជាតា ជាអ្នកសហការប្រព្រឹត្តយ៉ាងសកម្ម



Scanned with CamScanner

និងជាអ្នកយកប្រាក់ដុល្លារអាមេរិកដែលឈ្មោះ [redacted] វឌ្ឍននារីរតន៍ បានកិបកេងបានសម្រេចនោះទៅប្តូរជាប្រាក់រៀលវិញ។ លុះដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ ខាងធនាគារកាណាឌីយ៉ា ក.អ បានស្រាវជ្រាវរកឃើញថា ឈ្មោះ [redacted] វឌ្ឍននារីរតន៍ បានកែបំបាត់ប្រាក់ធនាគារកាណាឌីយ៉ា ក.អ ជាច្រើនលើក ទើបខាងធនាគារដាក់ពាក្យបណ្តឹងអ្នកទាំង ០២នាក់ ប្តីប្រពន្ធខាងលើ ហើយសមត្ថកិច្ចបានឃាត់ខ្លួនអ្នកទាំង ០២នាក់ និងកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធី និងបានប្តឹងបច្ចពូកជាបន្តបន្ទាប់។

**បានឃើញ : សាលក្រមព្រហ្មទណ្ឌលេខ ១១១៨ "លប" ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖**

១-កែប្រែបទចោទប្រកាន់លើឈ្មោ [redacted] បញ្ញាសុជាតា ភេទស្រី អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ ពីបទ **វិលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬ បុគ្គលផ្សេងទៀត** ប្រព្រឹត្តនៅចំណុចស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក ផ្លូវព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីដើមខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ មកជាបទ **សមគំនិតក្នុងអំពើវិលោភលើទំនុកចិត្តពិសេស ដោយអភិបាល ឬ បុគ្គលផ្សេងទៀត** ប្រព្រឹត្តនៅចំណុចស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក ផ្លូវព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីដើមខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា ២៩ និងមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ។

២-ផ្តន្ទាទោស ៖

ក-ឈ្មោះ [redacted] វឌ្ឍននារីរតន៍ ភេទស្រី អាយុ ៣១ឆ្នាំ ជាតិខ្មែរ

ខ-ឈ្មោះ [redacted] រចនា ភេទស្រី អាយុ ៣៩ឆ្នាំ ជាតិខ្មែរ

គ-ឈ្មោះ [redacted] សុវណ្ណចរិយា ភេទស្រី អាយុ ៣០ឆ្នាំ ជាតិខ្មែរ

ឃ-ឈ្មោះ [redacted] សុធាយ ភេទសប្រុស អាយុ ៣១ឆ្នាំ ជាតិខ្មែរ

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល ០៤ (បួន)ឆ្នាំ ពីបទ **វិលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬ បុគ្គលផ្សេងទៀត** ប្រព្រឹត្តនៅចំណុចស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក ផ្លូវព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីដើមខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ។

៣-ផ្តន្ទាទោស ៖

ក-ឈ្មោះ [redacted] បញ្ញាសុជាតា ភេទស្រី អាយុ ៣១ឆ្នាំ ជាតិខ្មែរ

ខ-ឈ្មោះ [redacted] ស៊ីមន្តា ភេទប្រុស អាយុ ៣៩ឆ្នាំ ជាតិខ្មែរ

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល ០៤(បួន)ឆ្នាំ ពីបទ **សមគំនិតក្នុងអំពើវិលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬ បុគ្គលផ្សេងទៀត** ប្រព្រឹត្តនៅចំណុចស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក ផ្លូវព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីដើមខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា ២៩ និងមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ។

៤-ផ្តន្ទាទោសឈ្មោះ [redacted] ហៀង ភេទប្រុស អាយុ ៤៣ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០៣ (បី)ឆ្នាំ ០៦ (ប្រាំមួយ)ខែ ពីបទ សមគំនិតក្នុងអំពើវិលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬ បុគ្គលផ្សេងទៀត ប្រព្រឹត្តនៅចំណុចស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក ផ្លូវព្រះមុនីវង្ស សង្កាត់



Scanned with CamScanner

ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីដើមខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា ២៩ និងមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ។

៥-ឱ្យឈ្មោះ[redacted] វឌ្ឍននារីរតន៍, ឈ្មោះ[redacted] រចនា, ឈ្មោះ[redacted]សុវណ្ណចរិយា, ឈ្មោះ[redacted] សុឆាយ, ឈ្មោះ[redacted]បញ្ញាសុជាតា, ឈ្មោះ[redacted] ស៊ីមន្ថា និងឈ្មោះ[redacted]ហៀង រួមគ្នាសងសំណងជម្ងឺចិត្តជាប្រាក់ចំនួន ៥០០.០០០.០០០រ(ប្រាំរយលាន)រៀល ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណី ធនាគារកាណាឌីយ៉ា អ.ក ដែលមានលោក[redacted]ារស៍ ជាតំណាង តាមមាត្រា ៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៦-វត្ថុតាងចាប់យកមាន ៖

ក-រឹបអូសជាសម្បត្តិរដ្ឋនូវ ៖

ក.១-រថយន្តម៉ាក TOYOTA HIGHLANDER ពណ៌ស ស៊េរីឆ្នាំ២០០៩ ពាក់ស្លាកលេខ ភ្នំពេញ 2BF-3383 ចំនួន ០១គ្រឿង។

ក.២-ទូរស័ព្ទដៃម៉ាក NOKIA (ចុចពិល) ពណ៌ខ្មៅ(មិនដំណើរការ) ចំនួន ០១គ្រឿង។

ខ-ប្រគល់ម្ចាស់ដើមយកទៅប្រើប្រាស់ជាកម្មសិទ្ធិនូវ ៖ បន្ទះស៊ីឌីចំនួន ០១បន្ទះ។

សាលក្រមនេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០, ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ និងថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted]វឌ្ឍននារីរតន៍, ឈ្មោះ[redacted] រចនា, ឈ្មោះ[redacted]សុវណ្ណចរិយា, ឈ្មោះ[redacted]សុឆាយ, ឈ្មោះ[redacted]បញ្ញាសុជាតា, ឈ្មោះ[redacted] ស៊ីមន្ថា និងឈ្មោះ [redacted]ហៀង ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាស[redacted]ធារណៈ នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១។

ភាគីមានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់បានកំណត់។

បានឃើញ : សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ៣៥៤ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២១ របស់ឈ្មោះ[redacted]ហៀង សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១១១៨ "លប" ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូល នៃសេចក្តីសម្រេច។

បានឃើញ : សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ៣៦១ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២១ របស់លោក [redacted]ប៊ុន ធឿន ជាមេធាវីការពារក្តីឱ្យជនជាប់ចោទឈ្មោះ [redacted]សុឆាយ និងឈ្មោះ [redacted]សុវណ្ណចរិយា សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១១១៨ "លប" ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូល នៃសេចក្តីសម្រេច។

បានឃើញ : សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ៣៤៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១ របស់ឈ្មោះ[redacted]ហៀង សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១១១៨ "លប" ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូល នៃសេចក្តីសម្រេច។

បានឃើញ : សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ៣៤១ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១ របស់ឈ្មោះ[redacted] បញ្ញាសុជាតា សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១១១៨ "លប" ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូល នៃសេចក្តីសម្រេច។

បានឃើញ : សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ៣៤២ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១ របស់ឈ្មោះ[redacted] រចនា សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១១១៨ "លប" ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូល នៃសេចក្តីសម្រេច។

បានឃើញ : សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ៣៤៣ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១ របស់លោក[redacted] សុគន្ធ និងលោក [redacted]បុល ជាមេធាវីការពារក្តីឱ្យជនជាប់ចោទឈ្មោះ[redacted]វឌ្ឍននារីរតន៍ និងឈ្មោះ[redacted]មន្ថា សុំ



Scanned with CamScanner

ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១១១៨ “លប” ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូល នៃសេចក្ដីសម្រេច។

បានឃើញ : សេចក្ដីចម្លងបណ្ដឹងឧទ្ធរណ៍លេខ ៣៧២ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ របស់ឈ្មោះ [redacted] សុឆាយ សុំប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១១១៨ “លប” ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូល នៃសេចក្ដីសម្រេច។

បានឃើញ : របាយការណ៍សំណុំរឿងព្រហ្មទណ្ឌ របស់ចៅក្រមរបាយការណ៍សភាព្រហ្មទណ្ឌ នៃសាលាឧទ្ធរណ៍ភ្នំពេញ។

បានឃើញ : សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] វឌ្ឍននារីរតន៍, ចាន់ ស៊ីមន្ថា (វត្តមាន)
-មេធាវីការពារក្ដីលោក [redacted] សុគន្ធ និងលោក គិន វិបុល (វត្តមាន)
-ជនជាប់ចោទឈ្មោះ [redacted] បញ្ញាសុជាតា (វត្តមាន)
-មេធាវីការពារក្ដីលោក [redacted] ចន្ថុល (វត្តមាន)
-ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណចរិយា, ថោង សុឆាយ (វត្តមាន)
-មេធាវីការពារក្ដីលោក [redacted] ប៊ុនធឿន (វត្តមាន)
-ជនជាប់ចោទឈ្មោះ [redacted] រចនា (វត្តមាន)
-មេធាវីការពារក្ដីលោក [redacted] ប៊ុនរ៉ា (វត្តមាន)
-ជនជាប់ចោទឈ្មោះ [redacted] ហៀង (វត្តមាន)
-មេធាវីការពារក្ដីលោក [redacted] សម្បត្តិ (វត្តមាន)
-ដើមបណ្ដឹងរដ្ឋប្បវេណី ធនាគារកាណាឌីយ៉ា អ.ក (អវត្តមាន)
-មេធាវីការពារសិទ្ធិលោក [redacted] បុរមុនី និងលោកស្រី [redacted] សុខកនិកា (វត្តមាន)

-ជនជាប់ចោទឈ្មោះ [redacted] វឌ្ឍននារីរតន៍ បានឆ្លើយថា ខ្លួនប្ដឹងឧទ្ធរណ៍មកនេះមិនសុខចិត្តនឹងត្រង់ចំណុចសំណង ខ្លួនបានសងទៅម្ចាស់បំណុលរួចហើយ។ ខ្លួនទទួលស្គាល់យកប្រាក់ចេញពីធនាគារគោលបំណងដើម្បីចំណេញក្បាលកាក់ ខ្លួនចូលបម្រើការងារនៅធនាគារតាំងឆ្នាំ២០១៥ ខ្លួនយកលុយដុល្លារ ទៅដូរយកលុយរៀល ហើយយកទៅបង់ពន្ធចូលធនាគារដដែល។ ខ្លួនទើបតែប្រព្រឹត្តលើកដំបូង និងមិនដែលជំពាក់ប្រាក់គេទេ។ ខ្លួននៅតែរក្សាចម្លើយនៅសាលាដំបូងទុកជាបានការដដែល។ **សំណូមពរ** សុំឱ្យតុលាការជួយវិនិច្ឆ័យ និងសុំរួចពីបទចោទ។

-ជនជាប់ចោទឈ្មោះ [redacted] បញ្ញាសុជាតា បានឆ្លើយថា ខ្លួនប្ដឹងឧទ្ធរណ៍មកនេះមិនសុខចិត្ត ដោយសារខ្លួនគ្មានចេតនានោះទេ គឺគ្រាន់តែចង់បានចំណេញក្បាលកាក់។ ខ្លួនយកលុយពីឈ្មោះ [redacted] វឌ្ឍននារីរតន៍ ខ្លួនមិនបានធ្វើអ្វីទៀតទេ។ **សំណូមពរ** សុំតុលាការជួយបន្ធូរបន្ថយទោសខ្លះ និងកែប្រែបទចោទមកជម្មតាវិញ។

-ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណចរិយា បានឆ្លើយថា ខ្លួនរកភាពអយុត្តិធម៌ ខ្លួនគ្រាន់តែជាអ្នកពិនិត្យបង្កាន់ដៃរបស់ធនាគារទេ ហើយខ្លួនពុំធ្លាប់ឃើញប្រាក់ច្រើនយ៉ាងនេះដែរ។ ខ្លួនមានតួនាទីសួរអតិថិជនថាគាត់ចង់មកបង់ពន្ធប្រភេទណា ហើយទទួលប្រាក់បង់ពន្ធពីអតិថិជនបង់ទៅធនាគារ រួចចេញបង្កាន់ដៃធនាគារឱ្យអតិថិជន។ សំណូមពរ សុំឱ្យតុលាការជួយរកយុត្តិធម៌ ព្រោះខ្លួនមិនបានប្រព្រឹត្ត។

-ជនជាប់ចោទឈ្មោះ [redacted] រចនា បានឆ្លើយថា នៅថ្ងៃកើតហេតុខ្លួនបានសុំច្បាប់មិនមកធ្វើការទេ។ ខ្លួនមិនបានកិបកេងប្រាក់របស់ធនាគារថ្លៃបង់ពន្ធនោះទេ។ ខ្លួនដឹងដោយសារតែខាងអគ្គនាយកពន្ធដារ បានទាក់ទងមកខ្លួនថា មានក្រុមហ៊ុន ត័ន ហ៊្គ័ន ខនស្ត្រាក់សិន(ខេមបូឌា) ឯ.ក មកបង់ពន្ធអត់ឱ្យជួយឆែក មើលក្នុងប្រព័ន្ធ ហើយពន្ធដារគេដឹងដោយសារតែយើងផ្ញើរបាយការណ៍ទៅពន្ធសាររាល់ថ្ងៃ ចំណែកប័ណ្ណ បង់ប្រាក់ធនាគារមិនផ្ញើឱ្យពន្ធដារទេ។ ការកាត់ក្តីរបស់សាលាដំបូងមិនមានភាពយុត្តិធម៌ទេ ព្រោះនៅថ្ងៃ កើតហេតុខ្លួនបានដាក់ច្បាប់មិនបានមកធ្វើការទេ។ អ្នកទទួលបន្ទុកបន្តពីខ្លួននៅថ្ងៃកើតហេតុ ក៏គាត់ពុំបាន ដឹងរឿងដែរ។ **សំណូមពរ** សុំជួយរកយុត្តិធម៌ឱ្យខ្លួនផង។

-ជនជាប់ចោទឈ្មោះ [redacted] ហៀង បានឆ្លើយថា ខ្លួនគ្រាន់តែជាអ្នកសន្តិសុខដែលបុគ្គលិកប្រើឱ្យលើ ក។ បុគ្គលិកតែងតែប្រើខ្លួនលើកឥវ៉ាន់ពីជាន់ក្រោម ទៅជាន់លើ រាល់ពេលលើកឥវ៉ាន់បុគ្គលិកមិនដែល ប្រាប់ថាជារបស់អ្វីទេ។ ខ្លួនទទួលស្គាល់ថា បានទទួលលុយដើម្បីយកទៅទិញបាយហូប។

-ជនជាប់ចោទឈ្មោះ [redacted] សុធាយ បានឆ្លើយថា មានតួនាទីផ្នែកបច្ចេកទេសជត ជួយដោះ ស្រាយបញ្ហា ចំពេលលុយដែលឈ្មោះ [redacted] វឌ្ឍននារីរតន៍ យកទៅខ្លួនមិនបានដឹងដែរ។ នៅពេលធ្វើ សកម្មភាពខ្លួនអត់ដឹងអីទាំងអស់។

-ជនជាប់ចោទឈ្មោះ [redacted] ស៊ីមន្ថា បានឆ្លើយថា ខ្លួនប្តឹងឧទ្ធរណ៍មកនេះ ព្រោះខ្លួនមិនបានដឹង រឿងនេះទេ។ ប្រពន្ធរបស់ខ្លួនបានប្រើឱ្យខ្លួនជួយលើកឥវ៉ាន់ប្រហែល ២-៣ដងដែរ ខ្លួនបានជួយយក ដាក់ក្នុងឡាន។ ប្រពន្ធខ្លួនបានប្រាប់ថា លុយនេះដឹកយកទៅផ្ទះ ខ្លួនដឹងថា លុយនេះទុកសម្រាប់បង់ លុយចូលរដ្ឋ។ ខ្លួនពុំដឹងថា លុយនេះជាលុយដុល្លារ ឬ លុយរៀលទេ។

**-តំណាងមហាអយ្យការ បានធ្វើសេចក្តីសន្និដ្ឋានថា** ជនជាប់ចោទទាំង ៧នាក់ មានឈ្មោះ **ទៀង វឌ្ឍននារីរតន៍**, ឈ្មោះ [redacted] រចនា, ឈ្មោះ [redacted] សុវណ្ណចរិយា, ឈ្មោះ [redacted] សុធាយ, ឈ្មោះ [redacted] ស៊ីមន្ថា, ឈ្មោះ [redacted] បញ្ញាសុជាតា និងឈ្មោះ [redacted] ហៀង ត្រូវបានជាប់ចោទពីបទ រំលោភលើទំនុកចិត្តពិសេសដោយ **អភិបាល ឬ បុគ្គលផ្សេងទៀត** តាមចម្លើយរបស់ជនជាប់ចោទទាំង ៧នាក់ និងមេធាវីការពារក្តី ថា លុយ ដែលអតិថិជនយកមកបង់ពន្ធបានប្រគល់ឱ្យធនាគារវិញហើយ។ តែធនាគារកាណាឌីយ៉ាបានដាក់ពាក្យ ប្តឹងជនជាប់ចោទ និងសហចារី តាមមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ។ សូមឱ្យក្រុមប្រឹក្សាពិនិត្យ និង ពិចារណាផ្តល់ស្ថានសម្រាល។

**-លោក [redacted] ប៊ុនធឿន មេធាវីការពារក្តីឱ្យជនជាប់ចោទឈ្មោះ [redacted] សុវណ្ណចរិយា និងឈ្មោះ [redacted] សុធាយ បានធ្វើសេចក្តីសន្និដ្ឋានថា** កូនក្តីខ្លួនមានតួនាទីទទួលបន្ទុក ដាក់, ដក និងផ្ទេរប្រាក់។ បុគ្គលិក ទាំងអស់ពុំមានការផ្លាស់ប្តូរពីជាន់ទី១ ទៅជាន់លើនោះទេ។ នៅថ្ងៃកើតហេតុនោះគឺបង្កឡើងដោយឈ្មោះ [redacted] **វឌ្ឍននារីរតន៍** តែម្នាក់គត់។ ហើយឈ្មោះ [redacted] **វឌ្ឍននារីរតន៍** ក៏បានបញ្ជាក់ហើយថា មិនទាន់បាន ដាក់លុយចូលក្នុងធនាគារដែរ។ កាមេរ៉ាបានបញ្ជាក់ច្បាស់ពីការប្រគល់លុយ គឺជាទំនាក់ទំនងឯកជនតែ ប៉ុណ្ណោះ។ ហើយកូនក្តីខ្លួនមិនបានសមគំនិតជាមួយឈ្មោះ [redacted] វឌ្ឍននារីរតន៍ នោះទេ។ **សំណូមពរ** សុំ ឱ្យកូនក្តីខ្លួនរួចផុតពីបទចោទ។

**-លោក [redacted] សម្បត្តិ មេធាវីការពារក្តីឱ្យជនជាប់ចោទឈ្មោះ [redacted] ហៀង បានធ្វើសេចក្តីសន្និដ្ឋានថា** ខ្លួនបានសួរកូនក្តីខ្លួនឈ្មោះ [redacted] ហៀង ថា លុយដែលទទួលបានទុកគ្រាន់ទិញបាយហូប។ កូនក្តីខ្លួនមានតួ នាទីធម្មតា។ ឈ្មោះ [redacted] **វឌ្ឍននារីរតន៍** បានពឹងខ្លួនឱ្យជួយលើកឥវ៉ាន់ពីជាន់ក្រោម ទៅជាន់ទី៥ ដែល មានឈ្មោះ [redacted] **វឌ្ឍននារីរតន៍** បានចាំនៅជាន់ទី៥។ ការចោទប្រកាន់របស់សាលាដំបូងគឺពុំត្រឹមត្រូវទេ។ ស្នើសុំក្រុមប្រឹក្សាពិនិត្យពិចារណាលើអង្គហេតុ កូនក្តីខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ហើយលុយ



Scanned with CamScanner

ដែរបានទទួលនោះ គឺពុំបានទទួលពីអំពើប្រព្រឹត្តបទល្មើសដែរ។ សំណូមពរ សុំឱ្យកូនក្តីខ្លួនរួចផុតពីបទចោទ។

-លោក[redacted] សុគន្ធ និងលោក[redacted]បុល មេធាវីការពារក្តីឱ្យជនជាប់ចោទឈ្មោះ [redacted] វង្សនទីរតន៍ និងជនជាប់ចោទឈ្មោះ[redacted]ស៊ីមន្ថា បានធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីខ្លួនទទួលស្គាល់ពិតជាបានយកប្រាក់របស់ធនាគារ ទៅដូរដើម្បីបានចំណេញក្បាលកាក់តែប៉ុណ្ណោះ។ ឯឈ្មោះ [redacted] ស៊ីមន្ថា ជាប្តីរបស់ឈ្មោះ[redacted]វង្សនទីរតន៍ គាត់ពុំបានដឹងថាជាលុយ ឬ របស់អ្វីផ្សេងទេ។ នៅក្នុងសាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញ ក៏បានសម្រេចឱ្យគាត់នៅក្រៅឃុំបណ្តោះអាសន្នដែរ។ ហើយសព្វថ្ងៃកូនក្តីខ្លួនបានយកលុយបង់ចូលធនាគារវិញអស់ហើយ។ សំណូមពរ សុំបដិសេធសាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញ និងសុំឱ្យកូនក្តីខ្លួនរួចផុតពីបទចោទ។

-លោក[redacted]ប៊ុនរ៉ា មេធាវីការពារក្តីឱ្យជនជាប់ចោទឈ្មោះ[redacted]ចនា បានធ្វើសេចក្តីសន្និដ្ឋានថា តាមមាត្រា ៣២៩ នៃក្រមព្រហ្មទណ្ឌ ចំពោះបុគ្គលណាដែលបានសម្របសម្រួលក្នុងការប្រព្រឹត្តបទល្មើស តែកូនក្តីខ្លួនបានយកលុយទៅឱ្យធនាគារវិញហើយ។ នៅថ្ងៃកើតហេតុកូនក្តីខ្លួនពុំមានវត្តមានទេ។ សំណូមពរ សុំឱ្យកូនក្តីខ្លួនរួចផុតពីបទចោទ។

-លោក[redacted]ន្តុល មេធាវីការពារក្តីឱ្យជនជាប់ចោទឈ្មោះ[redacted]បញ្ញាសុជាតា បានធ្វើសេចក្តីសន្និដ្ឋានថា សុំឱ្យតុលាការកែប្រែបទចោទតាមមាត្រា ៣៩៣ មកបទល្មើស រំលោភលើទំនុកចិត្តធម្មតាវិញ។ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានស្ថាពរ ក៏មិនបានកែប្រែតាមមាត្រា ៣៩៣ និងមាត្រា ៣២៩ នេះដែរ។ កូនក្តីខ្លួនបានទទួលស្គាល់ពិតជាមានការពាក់ព័ន្ធជាមួយឈ្មោះ [redacted] វង្សនទីរតន៍ ពិតមែន។ សំណូមពរ ស្នើសុំក្រុមប្រឹក្សាកែប្រែបទចោទ តាមការស្នើសុំខាងលើ។

-លោក [redacted] បុរមុនី និងលោកស្រី [redacted] សុខកនិកា មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើសេចក្តីសន្និដ្ឋានថា ជនជាប់ចោទទាំង ៧នាក់ ពិតជាបានប្រព្រឹត្តអំពើមិនគប្បីក្នុងការកេងចំណេញប្រាក់ខ្លះពីធនាគារ។ ប្រសិនបើធនាគារមិនដឹង មិនបង្វិលចូលធនាគារវិញ ច្បាស់ជាជនជាប់ចោទកិបកេងជាមិនខាន។ សាលក្រមព្រហ្មទណ្ឌលេខ ១១១៨ "ល" ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលសម្រេចមកនេះមានលក្ខណៈត្រឹមត្រូវហើយ។ សំណូមពរ សុំតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១១១៨ "ល" ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
-ក្រោយពីបានពិនិត្យភស្តុតាងដែលពាក់ព័ន្ធនឹងរឿងក្តី
-ក្រោយពីបានពិនិត្យពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## <u>សភាព្រហ្មទណ្ឌ យល់ឃើញថា៖</u>

១-បណ្តឹងឧទ្ធរណ៍លេខ ៣៤៣ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២១ របស់ឈ្មោះ [redacted] សុគន្ធ និងលោក[redacted]វិបុល មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ ចាន់ ស៊ីមន្ថា និងឈ្មោះ [redacted]វង្សនទីរតន៍, បណ្តឹងឧទ្ធរណ៍លេខ ៣៤២ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ[redacted]ចនា, បណ្តឹងឧទ្ធរណ៍លេខ ៣៥១ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ[redacted]បញ្ញាសុជាតា, បណ្តឹងឧទ្ធរណ៍លេខ ៣៤៦ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted]



Scanned with CamScanner

ហៀង, បណ្ដឹងឧទ្ធរណ៍លេខ ៣៦១ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២១ របស់លោក[redacted]ប៊ុនធឿន មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted]សុឆាយ និងឈ្មោះ [redacted]សុវណ្ណចរិយា, បណ្ដឹងឧទ្ធរណ៍លេខ ៣៥៤ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ[redacted]ចាន់ស្រីយ៉ា និងឈ្មោះ[redacted] ហៀង ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១១១៨ "ល" ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្ដីសម្រេច បានធ្វើឡើងត្រឹមត្រូវក្នុងកំណត់ច្បាប់សភាព្រហ្មទណ្ឌទទួលជំនុំជម្រះបាន យោងតាមមាត្រា ៤៣ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ និងមាត្រា ៣៨២ថ្មី នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-ជនជាប់ចោទឈ្មោះ[redacted] វឌ្ឍននារីរតន៍ បានឆ្លើយសារភាពថា ខ្លួនមានមុខងារជាបុគ្គលិកនៅស្នាក់ការកណ្ដាលនៃធនាគារកាណាឌីយ៉ា ជាបេឡាករ ទទួលបន្ទុកផ្នែកប្រាក់ពន្ធ ដែលអតិថិជនយកប្រាក់មកបង់ពន្ធ តាមរយៈការវេរចូលគណនីរបស់អគ្គនាយកដ្ឋានពន្ធដារ។ ខ្លួនមានតួនាទី ទទួលប្រាក់ពន្ធ រាប់លុយ បញ្ចូលទឹកប្រាក់ទៅក្នុងប្រព័ន្ធធនាគារ រួចបំពេញទឹកប្រាក់នៅលើប័ណ្ណដាក់ប្រាក់របស់ធនាគារ និងបន្តបញ្ចូលទឹកប្រាក់ទៅក្នុងប្រព័ន្ធពន្ធដារ រួចព្រីនបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធជូនអតិថិជន។ នៅថ្ងៃកើតហេតុថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ ខ្លួនពិតជាបានធ្វើសកម្មភាពយកប្រាក់ចំនួន ៦.១៦០.០០០$ ដុល្លារអាមេរិកចេញពីធនាគារកាណាឌីយ៉ា ច្រកក្នុងថង់ខ្មៅចំនួន ០៣ថង់ រួចឱ្យឈ្មោះ[redacted] បញ្ញាសុជាតា ជាមិត្តភក្តិ នាំសន្តិសុខមកជួយជញ្ជូនប្រាក់ពីជាន់ផ្ទាល់ដីឡើងទៅជាន់ទី៥ នៃទីស្នាក់ការកណ្ដាល នៃធនាគារកាណាឌីយ៉ា ហើយប្រហែលជាកន្លះម៉ោងក្រោយមក ប្ដីរបស់ខ្លួនឈ្មោះ[redacted] ស៊ីមន្ថា ក៏មកដល់រួចក៏ជញ្ជូនថង់ប្រាក់ដាក់ចូលក្នុងឡានដឹកចេញទៅផ្ទះ។ ប្រាក់នេះ ជាប្រាក់ពន្ធរបស់ក្រុមហ៊ុន គន់ ហ្វ័រខនស្ត្រាក់សិន បានបង់ពន្ធជូនរដ្ឋតាមរយៈធនាគារ តែខ្លួនមិនបានបញ្ជូនប្រាក់នេះទៅក្នុងប្រព័ន្ធធនាគារទេ។ ខ្លួនធ្វើនេះ ដើម្បីបានចំណេញក្បាលកាត់ប៉ុណ្ណោះ រួចបង្វិលប្រាក់ចូលក្នុងធនាគារវិញ។ ដែលចំណុចនេះ គប្បីតុលាការពិចារណាតាមច្បាប់។

៣-ជនជាប់ចោទឈ្មោះ[redacted]បញ្ញាសុជាតា បានឆ្លើយសារភាពថា ខ្លួនមិនមែនជាបុគ្គលិកធនាគារកាណាឌីយ៉ាទេ។ នៅថ្ងៃកើតហេតុនោះ ខ្លួនពិតជាបានជួយយកប្រាក់ពីឈ្មោះ[redacted] វឌ្ឍននារីរតន៍ ទៅប្ដូរជាប្រាក់រៀលតាមការពឹងពាក់របស់ឈ្មោះ[redacted]វឌ្ឍននារីរតន៍ ជាមិត្តភក្តិ គ្រាន់បានចំណេញក្បាលកាត់ចែកគ្នាប៉ុណ្ណោះ។ លុយដែលយកនោះ ពួកខ្លួនបានបង្វិលចូលធនាគារវិញហើយ។ ដែលចំណុចនេះ គប្បីតុលាការពិចារណាតាមច្បាប់។

៤-ជនជាប់ចោទឈ្មោះ[redacted] សុវណ្ណចរិយា បានឆ្លើយថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ។ ខ្លួនមានតួនាទីជាអ្នកត្រួតពិនិត្យផ្នែកប្រាក់ពន្ធ និងជាអ្នកត្រួតពិនិត្យផ្ទាល់លើការងាររបស់បេឡាករទាំងអស់ដែលទទួលបន្ទុកប្រាក់ពន្ធពិតមែន តែខ្លួនមិនបានដឹងអំពីរឿងដែលចោទប្រកាន់មកលើខ្លួននោះទេ និងជនជាប់ចោទឈ្មោះ[redacted] រចនា ថា ខ្លួនក៏មិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ។ ខ្លួនមានតួនាទីជាអនុប្រធានប្រតិបត្តិស្នាក់ការកណ្ដាលនៃធនាគារកាណាឌីយ៉ា ទទួលបន្ទុកប្រាក់ពន្ធ និងគម្រោងរាជរដ្ឋាភិបាល និងជាអ្នកត្រួតពិនិត្យការងារទូទៅ ផ្នែកបង់ពន្ធត្រួតពិនិត្យលើការងាររបស់ឈ្មោះ[redacted]សុវណ្ណចរិយា និងជាអ្នកត្រួតពិនិត្យផ្ទៀងផ្ទាត់លើការងាររបស់បេឡាករទាំងអស់ ដែលទទួលបន្ទុកប្រាក់ពន្ធពិតមែន តែនៅថ្ងៃកើតហេតុនោះ ខ្លួនមិនដឹងទេ ពីព្រោះ ខ្លួនបានសុំច្បាប់ឈប់សម្រាកមួយថ្ងៃ។ ពេលខ្លួនចូលធ្វើការវិញប្រហែលប្រាំបីថ្ងៃក្រោយមក ទើបខ្លួនដឹង។ ខ្លួនមិនបានរាយការណ៍អំពីរឿងនេះទេ តែខ្លួនបាន

សម្រុះសម្រួលឱ្យឈ្មោះ [redacted] វឌ្ឍននារីរតន៍ បង្វិលប្រាក់ចូលធនាគារវិញ។ ដោយការបង្វិលប្រាក់ចូលធនាគារវិញមិនគ្រប់ចំនួន ទើបខ្លួនរាយការណ៍ និងជនជាប់ចោទឈ្មោះ [redacted] សុឆាយ បានឆ្លើយថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ។ ខ្លួនមិនទាក់ទងក្នុងរឿងនេះទេ។ លុយដែលធនាគាររកឃើញជាលុយរបស់ម្តាយខ្លួនលក់ដីបាន ឱ្យលុយខ្លួនដាក់ធនាគារ យកការប្រាក់។ ជនជាប់ចោទឈ្មោ [redacted] ហៀង បានឆ្លើយថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ។ នៅថ្ងៃកើតហេតុនោះ ខ្លួនពិតជាបានជួយយកថង់ពីជាន់ផ្ទាល់ដី ឡើងទៅជាន់ទី៥ នៃទីស្នាក់ការកណ្តាល នៃធនាគារកាណាឌីយ៉ាប្រាកដមែន។ តែខ្លួនមិនដឹងថា ក្នុងថង់នោះមានអ្វីទេ។ ខ្លួនជួយយកតាមការពឹងពាក់របស់ឈ្មោះ [redacted] វឌ្ឍននារីរតន៍ ដែលជាបុគ្គលិកធនាគារ។ ខ្លួនមានមុខងារជាសន្តិសុខ និងជាអ្នកបើកឡានឱ្យធនាគារ អ្នកណាក៏ខ្លួនជួយដែរឱ្យតែពឹងខ្លួន។ កន្លងមក គេពឹងឱ្យជួយលើកជួយយួរ ជួយទិញ បាយទឹក ខ្លួនជួយ ហើយគេឱ្យលុយខ្លះចាយ។ នៅថ្ងៃកើតហេតុនោះ ខ្លួនពិតជាបានទទួលលុយពីឈ្មោះ [redacted] វឌ្ឍននារីរតន៍ ពិតមែន តែខ្លួនមិនដឹងថា ប៉ុន្មាននោះទេ និងជនជាប់ចោទឈ្មោះ [redacted] ស៊ីមន្ថា បានឆ្លើយថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ។ នៅថ្ងៃកើតហេតុ ខ្លួនបានទៅដឹកប្រពន្ធរបស់ខ្លួនឈ្មោះ [redacted] វឌ្ឍននារីរតន៍ ចេញពីកន្លែងធ្វើការទៅផ្ទះ។ ខ្លួនបានយកថង់ខ្មៅដាក់ចូលក្នុងរថយន្តរបស់ខ្លួនមែន តែខ្លួនមិនដឹងថា ក្នុងថង់ខ្មៅនោះមានអ្វីទេ។ លុះចូលក្នុងឡានទើបប្រពន្ធរបស់ខ្លួនប្រាប់ថា ក្នុងថង់ខ្មៅនោះជាលុយ តែខ្លួនមិនចាប់អារម្មណ៍ ពីព្រោះ ជាការងាររបស់ប្រពន្ធខ្លួន។

ប៉ុន្តែ ចម្លើយរបស់ជនជាប់ចោទគ្រាន់តែជាចម្លើយដោះសារយករួចខ្លួនប៉ុណ្ណោះ តុលាការមិនអាចជឿបាន ពីព្រោះថា តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី បានឆ្លើយថា ឈ្មោះ [redacted] វឌ្ឍននារីរតន៍ ជាបុគ្គលិកនៅស្នាក់ការកណ្តាលនៃធនាគារកាណាឌីយ៉ា ជាបេឡាទទួលបន្ទុកផ្នែកប្រាក់ពន្ធ ដែលអតិថិជនបង់ពន្ធជូនរដ្ឋតាមរយៈការវេរចូលគណនីរបស់អគ្គនាយកពន្ធដារ។ នៅថ្ងៃកើតហេតុថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ វេលាម៉ោង ៩និង១០នាទី ជនជាប់ចោទរូបនេះបានទទួលប្រាក់ពីអតិថិជន ក្រុមហ៊ុន គ័ន ហ្គ័រ ខនស្ត្រាក់សិន ខេមបូឌា នៅបន្ទប់ទទួលភ្ញៀវ វី អាយ ភី ជាន់ផ្ទាល់ដី ចំនួន ៦.១៦០.០០០ដុល្លារអាមេរិក តែជនជាប់ចោទមិនបានបញ្ចូលសាច់ប្រាក់នោះទៅក្នុងប្រព័ន្ធធនាគារទេ។ ហើយរួមគំនិតគ្នាធ្វើសកម្មភាពនាំប្រាក់ចេញពីធនាគារ និងតាមសេចក្តីសន្និដ្ឋានរបស់មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី ចម្លើយរបស់ជនជាប់ចោទឈ្មោ [redacted] វឌ្ឍននារីរតន៍ និងជនជាប់ចោទឈ្មោះ [redacted] បញ្ញាសុជាតា បង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធលេខ ០០៨០៨៥៨៣៨ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ ដែលមានទឹកប្រាក់ចំនួន ២៤.៣៦៨.៦៣២.១៤៧រៀល និងបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធលេខ ០០៨០៨៥៨៣៩ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ ដែលមានទឹកប្រាក់ចំនួន ៣៨៨.០៣៦.៥២៧រៀល ដែលចុះហត្ថលេខាដោយឈ្មោះ [redacted] វឌ្ឍននារីរតន៍ និងរូបភាពដែលចាប់យកចេញពីកាមេរ៉ាសុវត្ថិភាពលេខ ៦៥.៥ ដល់ ៦៥.១៣ របស់ធនាគារកាណាឌីយ៉ា និងរបាយការណ៍បឋមផ្នែកសវនកម្មផ្ទៃក្នុងនៃធនាគារកាណាឌីយ៉ា មានលក្ខណៈស៊ីចង្វាក់គ្នា ដែលបង្ហាញឱ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] រចនា, ឈ្មោ [redacted] បុរ្ណចរិយា, ឈ្មោះ [redacted] សុឆាយ, ឈ្មោះ [redacted] ហៀង, ឈ្មោ [redacted] ស៊ីមន្ថា ពិតជាបានដឹងអំពីព្រឹត្តហេតុល្មើសច្បាប់ដែលប្រព្រឹត្តដោយសហចារី និងរួមគំនិតប្រព្រឹត្តអំពើកែបំបាត់ដោយចេតនាទុច្ចរិត បំពានមាត្រា ២៩ និងមាត្រា ៩៣ នៃក្រមព្រហ្មទណ្ឌ ដែលមានសព្វគ្រប់ក្នុងផ្នែកសំអាងហេតុនៃសាលក្រមព្រហ្មទណ្ឌលេខ ១៦៦៨ "ល" ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ បញ្ជាក់ស្រាប់។



Scanned with CamScanner

៥-មេធាវីតំណាងឱ្យដើមបណ្ដឹងរដ្ឋប្បវេណី បានធ្វើសេចក្ដីសន្និដ្ឋានថា នៅថ្ងៃកើតហេតុថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ វេលាម៉ោង ៩នឹង១០នាទី ឈ្មោះ [redacted]ឌ្ឍននារីរតន៍ ជាបុគ្គលិកផ្នែកទទួលប្រាក់ពន្ធ បានទទួលប្រាក់ពីអតិថិជន ក្រុមហ៊ុន តន័ ហ្គ័រ ខនស្រ្ដាក់ស៊ិន ខេមបូឌា នៅបន្ទប់ទទួលភ្ញៀវ វីអាយភី ជាន់ផ្ទាល់ដីចំនួន ៦.១៦០.០០០ ដុល្លារអាមេរិក តែមិនបានបញ្ចូលសាច់ប្រាក់នោះទៅក្នុងប្រព័ន្ធធនាគារទេ។ ហើយរួមគំនិតគ្នាធ្វើសកម្មភាពនាំប្រាក់ចេញពីធនាគារ។

៦-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានធ្វើសេចក្ដីសន្និដ្ឋានប្រហាក់ប្រហែលគ្នាថា កូនក្ដីខ្លួនមានតួនាទីទទួលបន្ទុក ដាក់, ដក និងផ្ទេរប្រាក់។ បុគ្គលិកទាំងអស់ពុំមានការផ្លាស់ប្ដូរពីជាន់ផ្ទាល់ដី ទៅជាន់ទី៥នោះទេ។ នៅថ្ងៃកើតហេតុនោះគឺបង្កឡើងដោយឈ្មោះ[redacted]ឌ្ឍននារីរតន៍ តែម្នាក់គត់។ ហើយឈ្មោះ[redacted]ឌ្ឍននារីរតន៍ ក៏បានបញ្ជាក់ហើយថា មិនទាន់បាន ដាក់លុយចូលក្នុងធនគារដែរ។ កាមេរ៉ាបានបញ្ជាក់ច្បាស់ពីការប្រគល់លុយ គឺជាទំនាក់ទំនងឯកជនតែប៉ុណ្ណោះ។ ហើយកូនក្ដីខ្លួនមិនបានសមគំនិតជាមួយឈ្មោះ [redacted]ឌ្ឍននារីរតន៍ នោះទេ។ ខ្លួនបានសួរកូនក្ដីខ្លួនឈ្មោះ [redacted]ហៀង ថា លុយដែលទទួលបានទុកគ្រាន់ទិញបាយហូប។ កូនក្ដីខ្លួនមានតួនាទីធម្មតា។ ឈ្មោះ [redacted]ឌ្ឍននារីរតន៍ បានពឹងខ្លួនឱ្យជួយលើកឥវ៉ាន់ពីជាន់ក្រោម ទៅជាន់ទី៥ ដែលមានឈ្មោះ[redacted] វឌ្ឍននារីរតន៍ បានចាំនៅជាន់ទី៥។ ការចោទប្រកាន់របស់សាលាដំបូងគឺពុំត្រឹមត្រូវទេ។ ស្នើសុំក្រុមប្រឹក្សាពិនិត្យពិចារណាលើអង្គហេតុ កូនក្ដីខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ហើយលុយដែរបានទទួលនោះ គឺពុំបានទទួលពីអំពើប្រព្រឹត្តបទល្មើសដែរ។ កូនក្ដីខ្លួនទទួលស្គាល់ពិតជាបានយកប្រាក់របស់ធនាគារ ទៅដូរដើម្បីបានចំណេញក្បាលកាក់តែប៉ុណ្ណោះ។ ឯឈ្មោះ[redacted]ស៊ីមន្ថា ជាប្ដីរបស់ឈ្មោះ[redacted]ឌ្ឍននារីរតន៍ គាត់ពុំបានដឹងថាជាលុយ ឬ របស់អ្វីផ្សេងទេ។ នៅក្នុងសាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញ ក៏បានសម្រេចឱ្យគាត់នៅក្រៅឃុំបណ្ដោះអាសន្នដែរ។ ហើយសព្វថ្ងៃកូនក្ដីខ្លួនបានយកលុយបង់ចូលធនាគារវិញអស់ហើយ។ តាមមាត្រា ៣២៩ នៃក្រមព្រហ្មទណ្ឌ ចំពោះបុគ្គលណាដែលបានសម្របសម្រួលក្នុងការប្រព្រឹត្តបទល្មើស តែកូនក្ដីខ្លួនបានយកលុយទៅឱ្យធនាគារវិញហើយ។ នៅថ្ងៃកើតហេតុកូនក្ដីខ្លួនពុំមានវត្តមានទេ។ សុំឱ្យតុលាការកែប្រែបទចោទតាមមាត្រា ៣៩៣ មកបទល្មើស រំលោភលើទំនុកចិត្តធម្មតាវិញ។ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានស្ថាពរ ក៏មិនបានកែប្រែតាមមាត្រា៣៩៣ និងមាត្រា៣២៩ នេះដែរ។ កូនក្ដីខ្លួនបានទទួលស្គាល់ពិតជាមានការពាក់ព័ន្ធជាមួយឈ្មោះ[redacted]ឌ្ឍននារីរតន៍ ពិតមែន។ ដែលចំណុចនេះ គប្បីតុលាការពិចារណាតាមច្បាប់។

៧-តំណាងមហាអយ្យការ ធ្វើសេចក្ដីសន្និដ្ឋានថា ជនជាប់ចោទទាំង ០៧នាក់ មានឈ្មោះ[redacted] វឌ្ឍននារីរតន៍, ឈ្មោះ[redacted]ចនា, ឈ្មោះ[redacted]សុវណ្ណចរិយា, ឈ្មោះ [redacted]សុឆាយ, ឈ្មោ[redacted]ស៊ីមន្ថា, ឈ្មោះ [redacted] បញ្ញាសុជាតា និងឈ្មោះ [redacted]ហៀង ត្រូវបានជាប់ចោទពីបទ រំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬ បុគ្គលផ្សេងទៀត តាមចម្លើយរបស់ជនជាប់ចោទទាំង ០៧នាក់ និងមេធាវីការពារក្ដីថា លុយដែលអតិថិជនយកមកបង់ពន្ធបានប្រគល់ឱ្យធនាគារវិញហើយ។ តែធនាគារកាណាឌីយ៉ាបានដាក់ពាក្យប្ដឹងជនជាប់ចោទ និងសហចារី តាមមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ។ ដែលចំណុចនេះ គប្បីតុលាការពិចារណាតាមច្បាប់។



Scanned with CamScanner

១០-សាលក្រមព្រហ្មទណ្ឌលេខ ១១១៨ "ល" ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលសម្រេចសេចក្តីមកនេះមានលើកសំអាងហេតុសព្វគ្រប់ និងមានលក្ខណៈត្រឹមត្រូវតាមច្បាប់ គួរសភាព្រហ្មទណ្ឌពិចារណា និងសម្រេចតម្កល់ទុកជាបានការតាមច្បាប់តទៅ។

**វិនិច្ឆ័យសេចក្តី**

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ៣៨៣ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២១ របស់ឈ្មោះ [redacted] សុគន្ធ និងលោក [redacted] វិបុល មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ស៊ីមន្ថា និងឈ្មោះ [redacted] វឌ្ឍននារីរតន៍, បណ្តឹងឧទ្ធរណ៍លេខ ៣៨២ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] រចនា, បណ្តឹងឧទ្ធរណ៍លេខ ៣៥១ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] បញ្ញាសុជាតា, បណ្តឹងឧទ្ធរណ៍លេខ ៣៨៦ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] ហៀង, បណ្តឹងឧទ្ធរណ៍លេខ ៣៦១ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២១ របស់លោក [redacted] ប៊ុនធឿន មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុធាយ និងឈ្មោះ [redacted] សុវណ្ណចរិយា, បណ្តឹងឧទ្ធរណ៍លេខ ៣៥៤ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] ចាន់ស្រីយ៉ា និងឈ្មោះ [redacted] ហៀង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់គតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១១១៨ "ល" ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ។

៣-បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] ស៊ីមន្ថា, ឈ្មោះ [redacted] វឌ្ឍននារីរតន៍, ឈ្មោះ [redacted] រចនា, ឈ្មោះ [redacted] បញ្ញាសុជាតា, ឈ្មោះ [redacted] ហៀង, ឈ្មោះ [redacted] សុធាយ និងឈ្មោះ [redacted] សុវណ្ណចរិយា តាមនីតិវិធីច្បាប់។

សាលដីកានេះ ជំនុំជម្រះនៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ស៊ីមន្ថា, ឈ្មោះ [redacted] វឌ្ឍននារីរតន៍, ឈ្មោះ [redacted] រចនា, ឈ្មោះ [redacted] បញ្ញាសុជាតា, ឈ្មោះ [redacted] ហៀង, ឈ្មោះ [redacted] សុធាយ និងឈ្មោះ [redacted] សុវណ្ណចរិយា កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី តែចាត់ទុកជាចំពោះមុខ។

បើកសិទ្ធិប្តឹងសាទុក្ខក្នុងកំណត់ច្បាប់។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted], [redacted] | [redacted] |

ឆ្មានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃព្រហស្បតិ៍ ១២ កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
សាលាឧទ្ធរណ៍ភ្នំពេញ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ ២០២១
ក្រឡាបញ្ជី

[redacted]



Scanned with CamScanner